# ការស្វែងយល់អំពីសង្គមស៊ីវិល

## ក្របខណ្ឌទស្សនាទាន៖

ថ្វីបើពាក្យថា "**សង្គមស៊ីវិល**" មានតាំងតែពីសម័យមុនមកក៏ដោយ សង្គមស៊ីវិលគឺជាក្រុមបញ្ញវន្ត ដែលធ្វើអោយ មានភាពរីកចំរើន ទៅលើភាពច្បាស់និងភាពដែលអាចយល់បានទទ្ទឹមនឹងការ មកដល់នៃភាព ទំនើបរបស់ប្រទេស ប៉ែកខាងលិច ក្នុងកំឡុងសតវត្សទី ១៧ ។ ចាប់តាំងពីទស្សនាទាន (គំនិតជារួម) "សង្គមស៊ីវិល" ត្រូវបានគេផ្តល់ អោយនូវអត្ថន័យជាច្រើន ហើយនិងឆ្លងកាត់ការពិនិត្យកែឡើងវិញជាច្រើនដង។ កាចាប់អារម្មណ៍យកចិត្តទុកដាក់ក្នុងសង្គមស៊ីវិលបានរីកដុះដាលឡើងដំណាលគ្នានឹងសម័យកាលនៃការដួលរលំនៃ របបកុម្មុយនិស្តនៅក្នុងប្រទេសអឺរ៉ុបខាងកើតនិងកណ្តាល។ ការកើតឡើងជាថ្មីនិងការប្រើប្រាស់ទស្សនាទាននេះ នៅក្នុងទស្សវត្សរកន្លងទៅ បានបណ្តាលឱ្យមានរបត់នៃការផ្លាស់ប្តូរដ៏មានសារៈសំខាន់មួយកកើតឡើង នៅក្នុងតួនាទីរបស់រដ្ឋហើយនឹងទីផ្សារ។

ការបកស្រាយផ្សេងៗអំពីសង្គមស៊ីវិល បានកើតមានឡើងនៅពេលជាមួយគ្នានោះដែរ ដូច្នេះហើយ ទើបអាច មានវិធីកត់សំគាល់បីយ៉ាង។ វិធីទីមួយ គឺត្រូវបានដកស្រង់សំខាន់ចេញពីប្រពៃណីអង់គ្លូ-អាមេរិកាំង ហើយបាន ប្រើប្រាស់សមិទ្ធិផលការងាររបស់ក្រុមថក់គ្វីល (Tocqueville) ។ ក្នុងវិធីនេះ សង្គមស៊ីវិល ត្រូវបាន គេមើលឃើញ ថាជាស្រទាប់កណ្តាល ដែលម្ខាងគឺរវាងជាមួយនឹងបុគ្គលនិងក្រុមគ្រួសារ ម្ខាងទៀតរវាងជាមួយនឹងស្ថាប័នរដ្ឋ ។ សូម្បីតែនៅទីណាដែលស្ថានបន័រដ្ឋបានវិវត្តនៅក្នុងទំរង់នៃគោលនយោបាយប្រជាធិបតេយ្យក៏ដោយ ក៏ពួកគេចាប់ផ្តើម បង្ហាញនូវទិដ្ឋភាពខុសៗគ្នានៃការខិតខំប្រឹងប្រែងរបស់មនុស្សដែលរួមមានទាំង សុខភាព ការអប់រំ សេវា សង្គម ហើយនឹងវិស័យផ្សេងៗគ្នាជាច្រើនដែលប្រជាពលរដ្ឋទំនាក់ទំនងជាមួយនិងរដ្ឋ ។ ទំរង់ដែលតំណាងអោយ ប្រជាធិបតេយ្យបង្កើតនូវរយៈចំងាយមួយ រវាងពីស្ថានបន័រដ្ឋហើយនឹងការ សំរេចចិត្តរបស់ស្ថាប័ន ទៅបុគ្គលនិង ក្រុមគ្រួសារដែលពុំមានអំណាច ។ ការកសាងនូវភាពសាមគ្គីភាព និងសមាគមនានា ឆ្លងកាត់តាមប្រជាពលរដ្ឋ ដើម្បីសំរុះសំរួលនិងចចារអំពីបំនងប្រាថ្នានិងផលប្រយោជន៏របស់ពួកគេជាមួយនឹងរដ្ឋ ។ ក្នុងកសាងទំរង់នេះ សង្គម ស៊ីវិលក្លាយជាវេទិកាមួយ សំរាប់បញ្ចេញទស្សនៈអំពីផលប្រយោជន៏ រួមរបស់ប្រជាពលរដ្ឋ ហើយនឹងសំរាប់ការ ផ្តល់សិទ្ធិអំណាចទៅអោយប្រជាពលរដ្ឋ ដើម្បីឱ្យគេ បញ្ចេញសំលេងផ្ទាល់ជាមួយនឹងស្ថាបន័រដ្ឋ។

អត្ថន័យទីពីរនៃសង្គមស៊ីវិល កើតចេញពីការការលំបាកប្រឈមមុខរវាងប្រជាពលរដ្ឋចំពោះ របបកុម្មុយ-និស នៅអឺរ៉ុបខាងកើត។ ប្រជាពលរដ្ឋចាប់ផ្តើមប្រឆាំងនឹងរដ្ឋកាន់អំណាច នៅក្នុងអឺរ៉ុបខាងកើតនិងអតីតសហភាពសូវៀត ម្យ៉ាងទៀតចំពោះ ការប្រើអំណាចផ្តាច់ការយោធានៅអាមេរិកឡាទីន ហ្វីល្លីពីន

និងអាហ្វ្រិកខាងត្បូង ម្យ៉ាងវិញទៀត ចលនាទាំងនេះបានបង្ហាញអោយឃើញពីបំនងប្រាថ្នា នៃកំលាំងរួមគ្នាពីបុគ្គលនានា ។ ការសំរុកចូលនៃចលនាទាំងនេះ គឺចង់អោយរដ្ឋមានប្រជាធិបតេយ្យ ហើយនិងបង្កើតនូវសេរីភាពបញ្ចេញមតិជាមូលដ្ឋាន ហើយនឹងសិទ្ធិសេរី ភាពសំរាប់ប្រជាពលរដ្ឋរបស់ពួកគេ ។ នៅក្នុងទំរង់បែបនេះ សង្គមស៊ីវិលចាប់ផ្តើមអោយធ្វើឱ្យមានសមភាពជា មួយនិងដំណើរការមានលទ្ធិប្រជាធិបតេយ្យ ក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធនយោបាយនានា។

វិធីទីបី គឺសំដៅចំពោះសញ្ញាណរបស់សង្គមស៊ីវិល ដែលមានឫសគល់ ក្នុងការរីកលូតលាស់នូវការឯកភាពជា សកលនៃទីផ្សារសេរី ហើយនឹងសហគ្រាសឯកជន ដែលជាក្បាលម៉ាស៊ីនសំរាប់អភិវឌ្ឍសេដ្ឋកិច្ច ។ ផ្នែកសាធារណៈ (ដែលមានរដ្ឋនិងស្ថានបន័រដ្ឋ) និងផ្នែកឯកជន (សំរាប់សហគ្រាសដើម្បីប្រាក់ចំណេញ) ដែលត្រូវបានឆ្លងកាត់ នូវការរៀបចំឡើងវិញនិងការផ្លាស់ប្តូរក្នុងតួនាទីនិងការចូលរួមចំណែកដែលពាក់ពន្ធ័របស់គេចំពោះការអភិវឌ្ឍន៍ សង្គម ។ ខណៈដែលមានសំនួរជាច្រើនចោទឡើង ស្តីពីតួនាទីនៃរដ្ឋក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ការវិវឌ្ឍន៏វី កចំរើន ខាងតំរូវការ សំរាប់ធ្វើឱ្យមានសេរីភាពសកម្មភាពសេដ្ឋកិច្ច ចេញពីការក្តោបក្តាប់អនុត្តរភាព (ការត្រួតត្រា) របស់រដ្ឋ ។ ក្នុងទំរង់នេះ តួអង្គទាំឡាយដែលពុំមែនជារដ្ឋ រួមមានសហគ្រាសឯកជនដើម្បីប្រាក់ ចំណេញ និងគ្រាន់ តែមានការបញ្ចូលនូវ សកម្មភាពសង្គមស៊ីវិលដែលមិនរកផលចំណេញ ។ ផ្នែកទីបី (បានបង្ហាញ អោយឃើញថា រដ្ឋគឺជាតួអង្គទី១ ហើយទីពីរគឺអង្គភាពអាជីវកម្ម) ការបង្កើតនេះនាពេលបច្ចុប្បន្នបានកំណត់ ទស្សនះឡើងវិញ ថាផ្នែកស៊ីវិល ជារបៀបរៀបរយសង្គម ។ ការយល់ អត្ថន័យ ហើយនឹងការស្តែងចេញខុសៗគ្នា ត្រូវបានផ្សារភ្ជាប់គ្នា ជាមួយនឹងពាក្យថា "សង្គមស៊ីវិល" នៅក្នុងបរិបទតំណាលគ្នា។

<u>សង្គមស៊ីវិលត្រូវបានកំណត់ន័យថា ជាការរួមបញ្ចូលគ្នានៃបុគ្គល ព្រមទាំងគំនិតផ្តួចផ្តើមរួមគ្នា ឆ្ពោះទៅការខិតខំ ប្រឹងប្រែងដើម្បីសមិទ្ធិផលសាធារណៈ</u> ។ និយមន័យនៃពាក្យសង្គមស៊ីវិល ត្រូវទទួលស្គាល់ចំពោះវត្តមានគំនិតផ្តួច ផ្តើមបុគ្គល ដែលមាននៅក្នុងវប្បធម៌ខុសៗគ្នា ។ ទោះបីជាសកម្មភាពបុគ្គលមានការកំនត់ យ៉ាងតិចតួចយ៉ាងណាក្តី ក៏វាបានចូលរួមវិភាគទានទៅក្នុងការរីកចំរើនសង្គមទាំងមូល។ នេះត្រូវបានពង្រឹងតាមរយៈសាសនាផ្សេងៗ ព្រមទាំងជំនឿប្រពៃណីក្នុងសង្គមខុសៗគ្នា និងក្នុងកាលប្រវត្តិសាស្ត្រផ្សេងៗគ្នា ។ គំនិតផ្តួចផ្តើមរួមនេះ ធ្វើឡើង ក្នុងទំរង់ខុសៗគ្នា និងកាលប្រវត្តិសាស្ត្រខុសៗគ្នា ។ នៅក្នុងបរិបទនាពេលបច្ចុប្បន្ននេះ ពួកគេបានយកនូវ ទំរង់ការទំនាក់ទំនងផ្សេងៗគ្នា ដែលពឹកផ្អែកលើលក្ខណៈនៃការទំនាក់ទំនងរវាង ប្រជាពលរដ្ឋ និងក្រុមគ្រួសារ ។ សព្វថ្ងៃនេះ មូលដ្ឋាននៃការទំនាក់ទំនងជាប្រពៃណីនៃវណ្ណៈ ជាតិពន្ធ សហគមន៏ ត្រូវបានផ្លាស់

ប្តូរច្រើនជាមួយ ការបញ្ចូលតំណាលគ្នាកាន់តែច្រើនឡើង ផ្អែកលើអ្នករស់នៅជិតខាង អ្នកជំនាញវិជ្ជាជីវៈ ឋានៈនិងកន្លែងការ ងារ ។

និយមន័យនេះបានចង្អុលអោយពីកិរិតផ្សេងៗនៃសមូហកម្មដែលអាចមាននៅក្នុងសង្គម ។ នៅពេលដែល គំនិតផ្តួច ផ្តើមរួមនានាកាន់តែត្រូវបានរៀបចំឱ្យមានលក្ខណៈផ្លូវការឡើង ហើយខ្លះទៀតត្រូវបានរៀបចំសំរាប រយៈពេលខ្លី ជាបណ្តោះអាសន្ន និងមិនផ្លូវការ ។

និយមន័យខាងលើ មើលចំពោះការបកស្រាយនានានៃសមិទ្ធិផលសាធារណៈ ។ សមិទ្ធិផល សាធារណៈនានា ជាកម្មសិទ្ធិរបស់ស្ថាបន័រដ្ឋជាលក្ខណៈប្រវត្តិសាស្រ្ត ដែលត្រូវបានគេហៅថាជា ស្ថាបន័រដ្ឋ និងនិមិត្តិកម្មនយោបាយ ។ ជាមួយនឹងមានលំអៀងនៃស្ថាបន័រដ្ឋផង ព្រមទាំងការរីកលូតលាស់នូវភាពខុស គ្នាក្នុងតំរូវការនិងផលប្រយោជន៏នៃ ប្រជាពលរដ្ឋផ្សេងៗផង គេពុំអាចរក្សាចំពោះការទទួលខុសត្រូវ ដល់សមិទ្ធិផលសាធារណៈតទៅទៀតនៅក្នុង ដៃនៃស្ថាបន័រដ្ឋបានទេ ។ម្យ៉ាងវិញទៀតសមិទ្ធិផល សាធារណៈ មិនមែនជាទស្សនៈរួមដូចៗគ្នា ហើយមនុស្សក្នុងផ្នែកផ្សេងៗគ្នា គេអាចនឹងបកស្រាយអំពីសមិទ្ធិផល សាធារណៈខុសគ្នា ។ រឿងនេះអាចនឹងប្រែប្រួលការពិតជាក់ ស្តែងនៅមូលដ្ឋានទៅដល់បញ្ហាសាកលលោក ។

រឿងនេះឈានចូលទៅកាន់សមិទ្ធិសង្គម ដោយហេតុនេះហើយនាំអោយមានភាពខុសគ្នា មានទំនាស់និង កាប្រជែងគ្នា ក្នុងន័យសមិទ្ធិផលសាធារណៈ មិនមែនតែក្នុងចំណោមឋានៈខុសៗគ្នានោះទេ ប៉ុន្តែវាស្ថិតនៅក្នុងក្រុម ដែលចាញ់ប្រៀបខាងសេដ្ឋកិច្ចនិងសង្គម ដែលសារធាតុដើមនៃសមិទ្ធិផលសង្គមមានលក្ខណៈប្លែកៗ ។ ជាលទ្ធផល សង្គមស៊ីវិលបានក្លាយជាកន្លែងដែលកសាងនូវសមិទ្ធិផលសាធារណៈទូទៅ គឺជាដំណើរការនៃការខិតខំប្រឹងប្រែង រវាងផ្នែកផ្សេងៗនៃសង្គម ។

ការឈានទៅរកការយល់ដឹងពីសង្គមស៊ីវិលខាងលើនេះ បានបង្ហាញនូវភាពជាក់ស្តែងថែមទៀតដែលនេះមិ នមែន ជាទស្សនទានគុណធមិដែលលើកស្ទួយផលប្រយោជន៏ និងសុភមង្គលទាំងអស់នោះទេ ។ មានភាពខុសគ្នា ជាច្រើន ហើយនិងទំនាស់ដែលស្ថិតក្នុងសង្គមស៊ីវិល ហើយក៏មានវិសមភាពនានាហើយនឹងអានុភាពអនុត្តរភាព ធ្វើប្រតិបត្តិ លើមុខងារនៅក្នុងសង្គមស៊ីវិលដែរ ។ នេះជាការពិតដែលមាននៅក្នុងកិរិតមូលដ្ឋាននិងថ្នាក់ជាតិ ដែលបានកើតមាន ឡើងក្នុងសង្វៀនអន្តរជាតិ ។

ភាពខុសគ្នាដាច់ស្រឡះមួយ ដែលបានបង្កើតឡើងចន្លោះព្រំដែនកំណត់និងមុខងាររបស់រដ្ឋហើយនឹង សង្គមស៊ីវិល ។ វាមានសារៈសំខាន់ណាស់ដែលកត់សំគាល់ថា ពេលដែលសង្គមស៊ីវិលខំរក្សានូវស្វ័យភាពចេញពីរដ្ឋ ស្វ័យភាពនោះកំរមានពេញលេញណាស់ ។ យើងក្រឡេកមើលសង្គមស៊ីវិល ព្រំដែនកំណត់ដែលស្វ័យភាព ទាក់ទងគ្នាដូចព្រំដែន កំណត់រដ្ឋនិងសង្គមស៊ីវិលមានភាពស្រពិចស្រពឹល ។

និយមន័យសង្គមស៊ីវិលរបស់យើងពុំគ្រាន់តែបញ្ចូលទាំងអង្គភាពផ្លូវការទេ ប៉ុន្តែថែមទាំងជាអង្គ ភាពមិនមែនផ្លូវការផងដែរ ។ មានការទំនាក់ទំនងយ៉ាងទូលំទូលាយ ដែលរួមមានបណ្តាញ និងសម្ពន្ធ័ភាពដែលមានក៏រិតខុស១គ្នា នៃការចងក្រងបង្កើត ។ ហើយមួយចំនួនទៀតមានការខ្វះខាត់ការរៀបចំទំរង់អង្គភាព។ ក្រុមជាច្រើនបានលើក ឡើងនូវបញ្ហាសំខាន់១ដូចជា ព្រៃឈើ សិទ្ធិមនុស្សដែលពឹងផ្អែក ការរស់នៅលើព្រៃឈើធ្វើការត្រួតពិនិត្យលើការ ថយចុះនៃព្រៃឈើ សិទ្ធិរបស់កុលសម្ព័ន្ធការដាំដុះលើដីព្រៃ ដែលត្រូវគេទន្ទ្រានយក ។ល ។

មានអង្គភាពមួយចំនួនដែលជំរុញអោយអ្នកដទៃដើរតួនាទីយ៉ាងមានប្រសិទ្ធភាព ដោយការផ្តល់អោយនូវការទំនុកបំរុង ដូចជាការជឿជាក់សប្បុរសធម៌ អង្គការអភិវឌ្ឍដោយស្ម័គ្រចិត្ត ។ល ។ នេះធ្វើអោយអន្តរការីជាច្រើនដែលយើងចង់បាន ឱ្យស្ថិតនៅក្នុងលក្ខណៈទូលំទូលាយជាសង្គមស៊ីវិល ។

## សមាគមសង្គមស៊ីវិល

ទំរង់ណាមួយក៏ដោយ គឺផ្អែកលើប្រព័ន្ធចំណាត់ថ្នាក់ ការចាត់ថ្នាក់របស់សង្គមស៊ីវិលបានប្រើប្រាស់នូវគោលបំណង ដូចជា ប្រភេទ សកម្មភាព លក្ខណៈរបស់អង្គភាព ការផ្អែកលើធនធានរបស់គេ ។ អ្វីដែលបានលើក ឡើងនៅទីនេះ គឺជាវិធីដែលចាប់យកនូវរបៀបផ្សេង១គ្នា ។ ការកំណត់ន័យនៃទស្សនាទាននៅក្នុងទំរង់នេះគឺជាប្រភេទទំនាក់ ទំនងប្រជាពលរដ្ឋ ដែលមាននៅក្នុងសង្គម ។

ការអនុវត្តន៍នូវក្របខណ្ឌ័ការងារទំនាក់ទំនងនេះ គឺជាមូលដ្ឋានធ្វើចំណាត់ថ្នាក់របស់ សង្គមស៊ីវិលរួមទាំងចរិតកិច្ច ការដំណើរការព្រមទាំងគោលបំណងនៃការទំនាក់ទំនង ដែលចាំបាច់រក្សាជាទស្សនៈ ។ ជាក់ស្តែងជំរើសបុគ្គល ដើម្បីទំនាក់ទំនងត្រូវបានអនុវត្តក្នុងបរិបទសង្គមវប្បធម៌កំណត់មួយ ។ ក្នុងសង្គមនៃកាលសម័យដើមជំរើសបុគ្គល មិនត្រូវបានប្រើក្នុងសេរីភាពពេញលេញនោះទេ ដែលមានដូចជាក្រុមគ្រួសារសហគមន៍ហើយនឹងសង្គម បានប៉ាន់ប្រមាណសមរម្យ និងដាក់ក៏រិតកំណត់នូវអានុភាពការប្រើប្រាស់ជំរើសទាំងនេះ ។ ហេតុនេះ ការចាត់ថ្នាក់នៃសង្គមស៊ីវិលនៅខាងក្រោមនេះ ដែលជាការទំនាក់ទំនងមួយ ដែលមានលក្ខណៈកាត់ក្លាយជាច្រើន ប្រភេទផងដែរ ។

ប្រភេទទាំងប្រាំនៃការទំនាក់ទំនង ដែលត្រូវបានពិនិត្យយ៉ាងល្អិតល្អន់នៅខាងក្រោម :

### ១-សមាគមប្រពៃណី

សមាគមបែបនេះស្ថិតនៅជុំវិញសង្គមមួយ ដោយកំណត់ដោយកុលសម្ព័ន្ធ ជាតិពន្ធ ឬវណ្ណៈមួយ ។ សហគមផ្សេង១គ្នានេះទទួលភារៈនៃមុខងារជាច្រើនក្នុង ជីវភាពរបស់ប្រជាពលរដ្ឋ ។ ក្រៅពីការសំរុះសំរួលទំនាក់ទំនងរវាងគ្រួសារនិងគ្រួសារ ការទំនាក់ទំនងនេះបានបង្កើតនូវប្រព័ន្ធយ៉ាងល្អិតល្អន់ បទដ្ឋាន និងនីតិវិធីអភិបាល

ការប្រើប្រាស់ ហើយនិងការការពារធនធានធម្មជាតិ ។ ក្នុងការរីកចំរើនរយៈពេល៥ទស្សវត្សមកហើយ សមាគមបែបនេះជាច្រើន បានចុះអន់ថយឬបំបែកចេញពីគ្នាដោយមូលដ្ឋាននៃភាពសមស្របខាងផ្លូវច្បាប់ ហើយនឹងធនធានរបស់ពួកគេត្រូវបានធ្វើឱ្យបរាជ័យដោយភ្នាក់ងារនានាជាច្រើនរបស់រដ្ឋ ។ កំលាំងជ្រាតចូលនៃទំនើបកម្មនិងនាយទុនបានធ្វើឱ្យកាន់តែចុះខ្សោយថែមទៀតនូវសមាគមបែបនេះ ។ ក្នុងតំបន់កុលសម្ព័ន្ធជាច្រើន សមាគមនីបែបនេះនៅមាននៅឡើយ ។ ការខិតខំព្យាយាមសំខាន់ៗជាច្រើន ដើម្បីការពារនិងបង្កើនសិទ្ធិទំនៀមទំលាប់ របស់ក្រុមកុលសម្ព័ន្ធ ទៅលើធនធានធម្មជាតិ នៅក្នុងតំបន់នានានៃប្រទេស ដែលត្រូវ បានដឹកនាំដោយសមាគមនានា។

**២-សមាគមសាសនា**

ជាច្រើនសតវត្សមកហើយ និកាយថ្មី និងសាសនាជាច្រើនបានកើតឡើង ហើយលាយឡំចូលគ្នាទៅក្នុងជីវភាពរស់នៅរបស់ប្រជាជនឥណ្ឌា។ សាសនាព្រះពុទ្ធ សាសនាជេន សាសនាសិឃី ហើយនិងមានសាសនាហិនណ្ឌូផ្សេងៗទៀត សាសនាយូដា សាសនាគ្រឹះ និងសាសនាអ៊ីស្លាម ដើម្បីធ្វើការកែទំរង់និងការបង្កើតថ្មី ។ សប្បុរសធម៌ជួយដល់ជនក្រីក្រខ្វះខាត ការផ្តល់សេវាចំពោះអ្នកក្រីក្រ ហើយនឹង "ដាន៍" (ការដាក់ទាន) ត្រូវបានណែនាំទូន្មានដូចគ្នា ដោយសាសនា និងនិកាយទាំងនេះ ។ ដូចនេះ អង្គការសង្គមស៊ីវិលផ្សេងជាច្រើន មានគោលបំណងប្រាថ្នាខាងផ្លូវសាសនា និងផ្លូវគំនិតច្បាស់លាស់ ព្រមទាំងសិទ្ធិអនុវត្ត។ សកម្មភាពមនុស្សចំពោះការអប់រំ ការថែទាំសុខភាព ការបរិ ភោគទឹក ការដាំដុះព្រៃឈើ និងសុខុមាលភាពសង្គមជាដើម រៀបចំចាត់ចែងយ៉ាងត្រឹមត្រូវគឺទីណាដែល សកម្មភាពសង្គមស៊ីវិលត្រូវបានអនុវត្តន៍ ដោយអង្គការសង្គមស៊ីវិលសាសនា។

បេសកម្មអប់រំរបស់រ៉ាម៉ាគ្រឹះស្នា និងកម្មវិធីថែទាំសុខភាពនៅខលខាត់តា ផ្នែកសេវាកម្មសង្គមរបស់មេបុព្វជិត សាសនាផ្សេងៗក្នុងផ្នែកផ្សេងៗនៃប្រទេសឥណ្ឌា ម៉ាដារ៉ាសា (សាលារៀន) និងយូណានី (ប្រពៃណី) គ្លីនិកឱសថ ដោយគ្រឹះស្ថានអ៊ីស្លាម សាលារៀន សៃបាបា ហើយកម្មវិធីទឹកបរិភោគ នៅក្នុងអេនដ្រា ប្រាដេសជាឧទាហរណ៍ លើកឡើងខ្លះ។ អ្នកបួសនិកាយយេស៊ូអ៊ីត ផ្នែកទេវវិទ្យាសេរីភាព ដែលមានអានុភាពដល់សហព័ន្ធអ្នកនេសាទ ដែលដឹកនាំយុទ្ធនាការនានាជំរុញឱ្យគោលនយោបាយរបស់រដ្ឋាភិបាល ការពារនិងបង្កើននូវផលប្រយោជន៍អ្នក នេសាទមួយក្រុមតូច ហើយនឹងជីវភាពប្រកបដោយនិរន្តរភាព អ្នករស់នៅតាមតំបន់ឆ្នេរសមុទ្រ ខិរ៉ាឡា តាមីល ណាឌូ និងអេដ្រាប្រាដេស។

**៣-ចលនាសង្គម**

នៅក្នុងបរិបទនាសម័យកាលនោះ ចលនាសង្គមមួយចំនួនបានស្តែងឡើងជាបាតុកម្មនានារបស់សង្គមស៊ីវិល ។ ចលនា ទាំងនេះមានច្រើនប្រភេទ ។

ក- ផ្នែកទីមួយ ជាសំខាន់ផ្តោតលើតំរូវការ និងផលប្រយោជន៏របស់ក្រុមមនុស្សជាក់លាក់មួយ។ ជាប្រវត្តិសាស្ត្រ សង្គមឥណ្ឌាបានគាបសង្កត់ទៅលើកុលសម្ព័ន្ធ (អ្នកស្រុកដើម) ក្រុមនិកាយតំបន់ភ្នំ (ដែលគេពុំប៉ះពាល់បាន) និងស្ត្រីភេទ ។ នៅក្នុងទស្សវត្សរកន្លងទៅ ចលនាសង្គមបានផ្តោតលើ ផលប្រយោជន៏ ក្តីបារម្ភ និងបំណងប្រាថ្នា របស់កុលសម្ព័ន្ធ ក្រុមនិកាយតំបន់ភ្នំ ហើយនិងស្ត្រីបានធ្វើអោយទទួលបាននូវអំណាចវិញ។

ខ- ទំរង់ផ្សេងៗទៀតនៃចលនាសង្គម ត្រូវបានតវ៉ាប្រឆាំងទៅនឹង ការអនុវត្តន៏ ស្ថាប័ន នយោបាយ ឬកម្មវិធី។ ចលនា សង្គមខ្លះធ្វើការកែទំរង់សង្គមអសីលធម៌ ជាពិសេសការប្រើសុរា ទារបណ្ណាការពីស្ត្រី និងសិទ្ធិរបស់ស្ត្រីក្នុងការទទួលមរតក ។

គ- គំរូនៃការអភិវឌ្ឍន៏និងកម្មវិធីបានផ្តល់លទ្ធផលការផ្លាស់ប្តូរធំៗ ជាពិសេសការផ្លាស់ប្តូររបស់កុលសម្ព័ន្ធ ហើយនឹងតំបន់ក្រីក្រដាច់ស្រយាល ។ ចលនាសង្គមស្តែងចេញនូវការតវ៉ាប្រឆាំង ឬការពារនូវការផ្លាស់ប្តូរដោយ សារការអភិវឌ្ឍន៏ ។ បញ្ហាជាច្រើនដែលស្ថិតក្នុងការការពារ ការអភិរក្ស និងការការពារបរិស្ថាន ជំរុញចលនា សង្គមទូទាំងប្រទេសផងដែរ។

ឃ- ចំនុចទីបួននៃចលនាសង្គម បានផ្តោតលើអភិបាលកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋ ។ យុទ្ធនាការប្រយុទ្ធប្រឆាំងទៅនឹងអំពើពុករលួយនៅក្នុងមន្ទីររដ្ឋាភិបាល យុទ្ធនាការសិទ្ធិសេរីភាពស៊ីវិលនិងសិទ្ធិមនុស្ស យុទ្ធនាការក្នុង ការទទួលពត៌មាន សិទ្ធទទួលការអប់រំ សិទ្ធិចិញ្ចឹមជីវិត គឺជាឧទាហរណ៏ក្នុងចំនុចនេះ។

ជាក់ស្តែងណាស់ គេពុំអាចចែកប្រភេទចលនាសង្គមឱ្យបានប្រសើរនោះទេ ។ មានការប្លែកគ្នាជាច្រើនក្នុងទស្សនៈនិងវិធីសាស្ត្រនានា នៅក្នុងគន្លងខុសៗគ្នា នៃចលនាសង្គមជាក់លាក់មួយ។ លក្ខណៈដើមនៃការរួមបញ្ចូលគ្នាដោយបុគ្គលនិងអង្គភាព ត្រូវបានកំនត់ដោយទស្សនៈនិងវិធីសសាស្ត្រនៃគន្លងចលនាសង្គមជាក់លាក់មួយ។ នេះវាមានន័យថា កំរិតខ្ពស់នៃការចូលរួមដោយស្មគ្រចិត្ត ដែលបង្ហាញពីចរិតលក្ខណៈនៃចលនាសង្គម ។ ភាពបណ្ដោះអាសន្ននៃការរួមគ្នា ការទាមទារស្នើសុំប្រកបដោយមនោគមវិទ្យាដ៏ប្រសើរ និងដោយផ្ទាល់នៃទស្សនៈនិងវិធីសាស្ត្រហើយនិងការប្តេជ្ញានៃថាមពលនិងធនធានបុគ្គល បានបង្កើតនូវលក្ខណៈដើមនៃការរួមគ្នានៅក្នុងចលនាសង្គមបង្ហាញអោយឃើញច្បាស់ ។ មុខងារបឋមសំខាន់នៃចលនាសង្គម ត្រូវបានកែទំរង់សង្គម ស្ថាប័ន និងអភិបាលកិច្ច ។ ទាំងនេះសំរេចជោគជ័យដោយការគៀងគរ ព្រមទាំងសតិសម្បជញ្ញៈរបស់ប្រជាពលរដ្ឋ ដែលចូលរួមក្នុងចលនានេះ។

## ៤- សមាជិកសមាគម

អង្គការសង្គមស៊ីវិលដែលជឿនលឿន រំពឹងអោយបុគ្គលចូលរួមជាមួយសមាគម។ អត្ថន័យទំនើបរបស់សមាគម គឺសមាជិកភាព។ នៅក្នុងអង្គការសង្គមស៊ីវិលទំនើបជាច្រើន ដែលលក្ខណៈវិនិច្ឆ័យនិងវិធីសាស្ត្រជ្រើសរើសសមាជិក សេវាកម្មនានាចំពោះសមាជិក ព្រមទាំងវិធីនៃការចូលរួមចំណែកវិភាគទានពីសមាជិកត្រូវបានដាក់ចេញយ៉ាង ច្បាស់លាស់។ កំរិតនៃភាពជាផ្លូវការក្នុងសមាជិកភាពហើយនឹងលក្ខណៈវិនិច្ឆ័យនៃការចូលរួមចំណែក ផ្លាស់ប្តូរ យ៉ាងខ្លាំងឆ្លងកាត់តាមប្រភេទនានានៃអង្គការសង្គមស៊ីវិល។

ក្នុងបរិបទបច្ចុប្បន្ននេះ ប្រភេទនៃសមាជិកភាពរបស់អង្គការសង្គមស៊ីវិលនានា អាចកំណត់ចេញដូចខាងក្រោម នេះ :

**ក) ភាពជាតំណាង**

អង្គការសមាជិកនានាបង្កើតឡើងជាបឋមធ្វើជាតំណាងឱ្យគំនិត ហើយនឹងផលប្រយោជន៍របស់ប្រជាពលរដ្ឋជាក់ លាក់មួយប្រភេទ ។ អាស្រ័យលើកំលាំងនៃចំនួនសមាជិករបស់ពួកគេ អង្គការសង្គមស៊ីវិលបែបនេះ មានបំណង ចង់បានសមាជិកភាពច្រើននិងទំហំមូលដ្ឋានធំ ដើម្បីទទួលបាននូវភាពដែលអាចមើលឃើញបាន ការបញ្ចេញសំលេង រួម ព្រមទាំងបង្កើននូវការចាប់អារម្មណ៍ជាផលប្រយោជន៍សាធារណៈ។

សហជីពកម្មករ គឺជាឧទាហរណ៍យ៉ាងច្បាស់មួយនៃប្រភេទបែបនេះ ។ ឧស្សាហកម្មចំរុះដ៏ធំមួយ មានសហជីព កម្មករ ដែលមានទីតាំង ការងារ និងមានជំនាញ នៅប្រតិបត្តការការងារសព្វថ្ងៃនេះ។ ដូចគ្នានេះដែរសហ ជីពកម្មករ នៅជនបទ កសិករ អ្នកលក់ និងកម្មការីនីជាដើម គឺជាឧទាហរណ៍ នៃផ្នែកសមាគមកម្មករ ធម្មតានៅប្រទេសឥណ្ឌា។

អង្គភាពក្រុមកសិករផ្សេងៗបង្កើតឡើងធ្វើជាតំណាងឱ្យផលប្រយោជន៍ឱ្យកសិករមួយចំនួនដែលមានទំហំ មធ្យម និងធំ ទៅនឹងរដ្ឋាភិបាល។ ការចចារនយោបាយ គឺជាគន្លឹះចំពោះវិធីដោះស្រាយរបស់សមាជិក ដែលពឹង អាស្រ័យ លើអង្គការសង្គមស៊ីវិល។

សមាគមគ្រឹះស្ថានពាណិជ្ជកម្មហើយនឹងសមាគមពាណិជ្ជករនានាមួយចំនួន ក៏ត្រូវកសាងអង្គភាពសមាជិក ដែរ ដើម្បីផលប្រយោជន៍សហគមន៍ពាណិជ្ជកម្ម ហើយនឹងគ្រឹះស្ថានពាណិជ្ជកម្ម ។ សមាគមទាំងនេះមានដូចជា សភាពាណិជ្ជកម្មនិងឧស្សាហកម្មថ្នាក់មូលដ្ឋាន តំបន់ និងថ្នាក់ជាតិ នៃពាណិជ្ជកម្ម និង ឧស្សាហកម្ម សម្ព័ន្ធ រួមគ្នានៃឧស្សាហកម្ម និងសហព័ន្ធសភាពាណិជ្ជកម្មនិងឧស្សាហកម្ម (អេហ្វ អាយ ស៊ី ស៊ី អាយ).។ល។ គឺជាឧទាហរណ៍នៃអង្គការសង្គមស៊ីវិល ។ អង្គការសមាគមទាំងនេះត្រូវបានទទួលស្គាល់ថា ជាសមាគមដែល មិនដើម្បីប្រាក់ចំណេញ ទោះបីសមាជិករបស់ពួកគេជានីតិបុគ្គលប្រតិបត្តិការរកប្រាក់ចំណេញក៏ដោយ។ ក្នុងឆ្នាំថ្មីៗ នេះ សមាគមអ្នកប្រើប្រាស់កំពុងតែចាប់ផ្តើមផុសចេញ ជាប្រភេទថ្មីនៃអង្គភាពសមាជិកនៅក្នុងប្រទេស។

**ខ) ជំនាញវិជ្ជាជីវៈ**

អង្គការសង្គមស៊ីវិលមួយចំនួនដែលមានស្រាប់ គឺជាអង្គការសមាជិកជុំវិញមុខរបរនិង/ឬក៏វិជ្ជាជីវៈជាក់លាក់ ។ ក្រុម មេធាវី គ្រូបង្រៀន អ្នកយកសារពត៌មាន វិជ្ជបណ្ឌិតព្យាបាល គិលានុបដ្ឋាយិកា វិស្វករ អ្នកចាត់ការ ទាំងអស់នេះមានសមាគមសមាជិករបស់គេ ។ សមាគមសុខាភិបាល សមាគមអ្នកចាត់ការ សហជីពអ្នកសារពត៌មានជាដើម គឺជាឧទាហរណ៍ខ្លះៗ ។ គោលបំណងបឋមរបស់ពួកគេគឺ ជំរុញការជឿនលឿននូវអត្តសញ្ញាណមុខរបរនិងវិជ្ជាជីវៈ និងការអាចមើលឃើញនៅក្នុងសង្គម ផ្តល់នូវឱកាសសំរាប់ផ្លាស់ប្តូរនិងគាំទ្រគ្នាចំពោះសមាជិក និងធានាសំលេងរួមក្នុងការទាមទារហើយនឹងក្តីបារម្ភ ។

**គ) វប្បធម៌សង្គម**

ក្លឹបមួយចំនួនសំរាប់គោលបំណងកីឡានិងលំហែ មាននៅក្នុងប្រទេសឥណ្ឌា។ ក្លឹបធំៗឯទៀតមានក្លឹបយីមខាណាដែលបំរើគោលបំណងសង្គមសំរាប់អ្នកទេព្យកោសល្យ។ ក្លឹបដែលជាសហគមសមាជិក ដែលត្រូវទៅតាមតំរូវការរបស់សមាជិកពួកគេ ផ្នែកខាងសង្គម វប្បធម៌ ហើយនឹងការលំហែកាយ។

ស្រដៀងគ្នានេះដែរ សមាគមខាងវប្បធម៌មាននៅក្នុងទំរង់ផ្សេងៗច្រើនផ្នែកនៅក្នុងប្រទេស ។ តន្ត្រីទំនើប រោងល្ខោន និងក្រុមរបាំនៅក្នុងទីក្រុងរួមជាមួយនឹងរបាំប្រពៃណី បទចំរៀង ក្រុមល្ខោននាដកម្ម នៅតំបន់ដាច់ស្រយាល។ ពួកគេបានបំរើដល់បំនងប្រាថ្នាសិល្បៈវិជ្ជា ហើយគាំទ្រដល់ជំនាញច្នៃប្រឌិតចំពោះសមាជិករបស់ពួកគេ។

**ឃ) ការជួយខ្លួនឯង**

ការរីកលូតលាស់នូវប្រភេទនានានៃសមាគមសមាជិក គឺជាក្រុមជួយខ្លួនឯងនៅមូលដ្ឋាននៅក្នុងសហគមន៍ជាក់លាក់។ ចាប់តពីគណៈកម្មាធិការដែលស្ថិតក្នុងតំបន់ក្រុងជិខាងទៅកាន់អង្គការមូលដ្ឋាន នៅក្នុងភូមិតូចៗ និងភូមិ ក្រុមអ្នកជួយខ្លួនឯងគឺមានចំនួនច្រើននៅសព្វថ្ងៃនេះ ។ ពួកគេជាច្រើនបានបង្កើតនូវទំរង់ដោយខ្លួនឯង ដើម្បីបំពេញសេចក្តីត្រូវ ការរបស់សមាជិកពួកគេ។ ក្រុមអ្នកជួយខ្លួនឯងបានចែករំលែកនូវធនធាន ជួយនិងគាំទ្រគ្នាទៅវិញទៅមក ព្រមទាំងកសាងកំលាំង។ ក្រុមអ្នកជួយខ្លួនឯងជាច្រើន ផ្តួចផ្តើមគំនិតដោះ ស្រាយនូវបញ្ហាដែលជួបប្រទះនៅក្នុងសហគមន៍របស់ពួកគេ ។

នៅក្នុងឆ្នាំថ្មីៗនេះ មានកម្មវិធីអភិវឌ្ឍជាច្រើនរបស់រដ្ឋាភិបាល និងអង្គការស្មគ្រចិត្តអភិវឌ្ឍន៍ (វិឌីអូ) ក៏បានជួយ ធ្វើឱ្យមានការកើតឡើងនូវអង្គការមូលដ្ឋាន ។ គណៈកម្មាធិការអប់រំភូមិ គណៈកម្មាធិការអនាម័យនិងទឹក ស្អាត គណៈកម្មាធិការការពារព្រៃឈើ ក្រុមការសន្សំនិងឥណទានខ្នាតតូច ។ល។ ជាឧទាហរណ៍នៃអង្គការមូលដ្ឋានដែលមានការជំរុញយ៉ាងខ្លាំងបំពេញបំណជួយខ្លួនឯងនៅកំរិតមូលដ្ឋាន ។ សហករណ៍ក៏ជាសមាគមសមាជិកនៃក្រុមជួយ ខ្លួនឯងដែរ។

**៥- អន្តរការី**

ប្រភេទនៃអង្គការសង្គមស៊ីវិលនេះ បាននាំយកអង្គការផ្សេងៗរួមគ្នាបំរើដល់មុខងារអន្តរការីក្នុងចំណោមប្រជាពលរដ្ឋម្នាក់ៗ និងរវាងពួកគេ ព្រមទាំងគ្រឹះស្ថានម៉ាក្រូរដ្ឋដូចជា របៀបចាត់ការរដ្ឋ តុលាការ អង្គនិតិបញ្ញតិ នគរបាល ។ល។ សមាគមបែបនេះត្រូវបានបង្កើតឡើងដោយក្រុមប្រជាពលរដ្ឋ (ជាទូទៅគឺអ្នកស្ថិតក្នុងវណ្ណៈកណ្តាល) ដើម្បីអោយជឿនលឿនទៅមុខហេតុផលសង្គមកាន់តែទូលំទូលាយឡើង ឬពង្រីកទូលាយនូវសមិទ្ធិផលសង្គម។ ប្រជាពលរដ្ឋបង្កើតឡើងនូវសមាគមអន្តរការី ពុំបានបំរើនូវរឿងផ្ទាល់ខ្លួនឬក៏តំរូវការផ្ទាល់ខ្លួននោះទេ ប៉ុន្តែទាំងអស់នេះបំរើឱ្យអ្នកដទៃនៃផ្នែកនៃសង្គមដ៏ធំទូលាយទៅវិញទេ ។ ប្រភេទនៃអង្គការអន្តរការីជាច្រើន បានធ្វើសកម្មភាពសព្វថ្ងៃនេះ។ ជាទូទៅ វាបានផ្តល់ឈ្មោះសំគាល់ថា អិន ជី អូ (អង្គការក្រៅរដ្ឋាភិបាល)។

**ក) ការផ្តល់នូវសេវាកម្ម**

អង្គការសង្គមស៊ីវិលដែលផ្តល់សេវាកម្មបំរើមនុស្សជាមូលដ្ឋាន បានផ្តោតលើការអប់រំ និងការថែទាំសុខភាព ។ សាលារៀន គ្លីនិក និងមន្ទីពេទ្យនានាធ្វើប្រតិបត្តិការ នៅក្នុងតំបន់ដាច់ស្រយាល និងទីក្រុងនៃប្រទេស។ វីឌីអូ បានពង្រីកការអភិវឌ្ឍន៍ក្នុងតំបន់គ្រប់គ្រងរបស់ពួកគេ រយៈពេល២ទស្សវត្សមកហើយ ។ កម្មវិធីទឹកស្អាត អនាម័យ មីក្រូឥណទាន ។ល។ ស្ថិតក្រោមការគ្រប់គ្រងរបស់ វីអូឌី សព្វថ្ងៃនេះ។ គ្រឹះស្ថានថែទាំនានា (ដូចជាកុមារកំព្រា អន្តេវាសិកសំរាប់ជនទុគតិ អន្តេវាសិកសំរាប់មនុស្សចាស់ជរា ។ល។) ត្រូវបានចាត់ចែងទទួលខុសត្រូវដោយ សមាគមនអន្តរការី។

**ខ-ការគៀងគរ**

អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានជួយចាត់ចែងនិងផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន និងផ្នែកអនុវាស្រ្តដើម្បីយល់ដឹង និងទាមទារសិទ្ធិរបស់ពួកគេ និងធ្វើជាម្ចាស់នៃការអភិវឌ្ឍន៍ខ្លួនឯង។ វិធីដោះស្រាយនេះអាចបញ្ចូលការផ្តល់សេវាកម្មផងដែរ ។ វិធីសាស្រ្តមួយចំនួននៃការអប់រំ និងរៀបចំចាត់ចែង ត្រូវបានប្រើប្រាស់ដោយ វីឌីអូ នៅតំបន់ផ្សេងៗនៃប្រទេស ដើម្បីធ្វើឱ្យអ្នកក្រីក្រ និងអនុវាស្រ្តធ្វើសកម្មភាពដោយខ្លួនឯង។

**គ-ការគាំទ្រ**

អង្គការសង្គមស៊ីវិល ដែលមានការពាក់ព័ន្ធជាច្រើន បានបង្កើតឡើងដើម្បីគាំទ្រដល់អង្គការសហគមន៍មូលដ្ឋានដ៏ទៃទៀត និង អង្គការពាក់ព័ន្ធដ៏ទៃទៀតដែលមានក្នុងប្រទេសឥណ្ឌាសព្វថ្ងៃនេះ។ មុខងារនៃការគាំទ្រ រួមបញ្ចូលទាំងការស្រាវជ្រាវ ហើយ ការចែកចាយពត៏មាន ការកសាងសមត្ថភាព និង សកម្មភាពបណ្តាញ។ មុខងានៃការគាំទ្រ គឺផ្តោតលើ គោលការណ៍ដូចជាការផ្តល់នូវប្រាក់ចំនូល បរិយាកាសសុខមាលភាព ការអភិវឌ្ឍដីលំនៅដ្ឋានទំនេរ ។ល។ អង្គការគាំទ្រមួយចំនួន គឺជាប្រភេទភ្នាក់ងារទូទៅ។

**ឃ-មនុស្សធម៌**

អង្គការសង្គមស៊ីវិលមួយចំនួន បានផ្តល់អោយធនធានទៅអោយអង្គការសង្គមស៊ីវិល នៅក្នុងប្រទេស ។ ការកែប្រែដ៏ធំទូលាយជាសកម្មភាពមួយក្នុងឆ្នាំថ្មីៗនេះ។ លំនៅដ្ឋានដែលធ្វើអាជីវកម្មជាច្រើន មានកម្មវិធីការមនុស្សធម៌ ។វិធីសាស្រ្តថ្មីត្រូវបានរកឃើញក្នុងការគៀគរធនធាន។

## ង- ការតស៊ូមតិ

អង្គការសង្គមស៊ីវិល បានបង្កើតនូវគោលបំនងតស៊ូមតិ នៅក្នុងករណីពិសេសលើ បរិស្ថាន យេនឌ័រ សិទ្ធិមនុស្ស និង កំលាំងពលកម្មកុមារ គ្រឹះស្ថានផានឆាយាទី រេជ (ភី អ អាយ) បានចេញផ្សាយនូវបញ្ហាមួយចំនួននៃការតស៊ូមតិរបស់ អង្គការសង្គមស៊ីវិល ដែលបានធ្វើសកម្មភាពថ្មីៗនេះ នៅប្រទេសឥណ្ឌា ។ភី យូ ស៊ី អិល (សហព័ន្ធប្រជាជនដើម្បីសេរីភាព) ស៊ី អេជ អរ អាយ (វិទ្យាស្ថានសិទ្ធិមនុស្ស) ដែលត្រូវបានធ្វើអោយមានកិត្តនាមនៅក្នុងចំនុចនេះ។

## ច-បណ្តាញ

អង្គការសង្គមស៊ីវិលមួយចំនួន ត្រូវបានចងជាសមាគមន៏របស់អន្តរការីដ៏ទៃទៀត ដោយធ្វើជាបណ្តាញដើម្បីប្រមូលបាននូវសំលេងមតិរបស់ពួកគេអោយមានភាពខ្លាំង។ បណ្តាញមួយចំនួនបានផ្តោតទៅលើចំនុចមួយនៃប្រភេទទាំងអស់នេះ បានស្ថិតក្នុងភូមិសាស្រ្តមួយពិតប្រាកដ។ បណ្តាញជាច្រើនបានពង្រីកសមាជិករបស់ពួកគេដើម្បីគ្របដណ្តប់ លើអន្តរការីយ៉ាងធំទូលាយ។

សរុបមក ដូច្នេះវាបានបង្ហាញអោយច្បាស់ថា ភាពទូលំទូលាយនៃអន្តរការីមាននៅសព្វថ្ងៃនេះ ។ពួកវាជាច្រើនបានរាប់រង នូវមុខងារជាច្រើន ដូចបញ្ជីខាងលើ។ ការចាត់ថ្នាក់យ៉ាងច្បាស់លាស់មួយ គឺមិនមានក្នុងសេចក្តីពិត ក្នុងចំណោមអន្តរការីទេ។ អង្គការតស៊ូមតិមួយចំនួន បានបង្កើតមុខងារជាច្រើន ដូចជាបណ្តាញ ត្រូវរាប់រងនូវការស្រាវជ្រាវ ហើយ និងជួយឧបត្ថមផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រភេទនៃអង្គការសង្គមស៊ីវិល បានរីកលូតលាស់ និងប៉ះពាល់ដល់គោលនយោបាយ ហើយនិងការអនុវត្តរបស់រដ្ឋាភិបាលនៅក្នុងប្រទេសសព្វថ្ងៃនេះ។

## សេចក្តីសន្និដ្ឋាន

ការប្រើប្រាស់ក្របខ័ណ្ឌការងារ ផែនការនៃសង្គមស៊ីវិល បានបង្ហាញអោយឃើញ នូវភាពទូលាយនៃផលប្រយោជន៏សាធារណ៏ ។ ដោយការបំរើផលប្រយោជន៏ជាពិសេសរបស់សហគមន៏ ឬ ក៏ក្រុមមួយដែលធ្វើអោយមានការបែងចែក ហើយ និងរួមបញ្ចូលនូវថ្នាក់កណ្តាល និង ថ្នាក់អធិបតី ដូចជា សមាគមន៏ផ្សេងៗដែលស្ថិតក្នុង ការតាក់តែងរបស់ពួកគេ នូវរចនាសម្ព័ន្ធ និង កិរិតផែនការ ការពង្រីកធនធាន និង គុណសម្បត្តិ នៃការចំណាយ។ នេះជាផែនការ ដែលបាន ណែនាំបានយ៉ាងល្អបំផុត នៃប្រភេទសមាគមន៏សព្វថ្ងៃនេះ។

ទោះបីជាយ៉ាងណាក៏ដោយ ការចាត់ថ្នាក់ខាងលើនេះ បានផ្តល់នូវគំនិតជាបុគ្គល ។ វាមិនបានចាប់យកអោយស្ថិតស្ថេរនោះទេ ដូចជាគណៈកម្មាធិការ ជំនឿ ជាប្រភេទដូចគ្នា ដែលមិនត្រូវគ្រប់ដណ្តប់អោយបានគ្រប់គ្រាន់ទៅលើផែនការនេះ ។ ផែនការនេះមិនបានកំរិតនូវស្វ័យភាព ប្រសិទ្ធភាព ការចូលរួមដោយស្មគ្រចិត្ត នៅក្នុងសមាគមន៏។ ថ្វីបើ ជាមានការកំនត់ នូវផែនការសង្គមស៊ីវិលមួយ បានផ្តោតលើធម្មជាតិ ហើយនិងការចូលរួមដោយស្មគ្រចិត្តនៅក្នុងសមាគមន៏ ក្នុងការផ្តល់អោយនូវផលប្រយោជន៏សាធារណៈ។